**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តត្បូងឃ្មុំ**

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៥៣
ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣
សាលក្រមរដ្ឋប្បវេណីលេខ **៥៤ "ក"**
ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តត្បូងឃ្មុំ

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃអង្គារ ២រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣។

-និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃពុធ ១០រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

*ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ*

**ក្រឡាបញ្ជីសវនាការ**

*លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ*

**+ដើមចោទ៖** [redacted] អាសយដ្ឋានអគារលេខ [redacted] ដោយមានលោក [redacted] ជាអ្នកតំណាង។

**+អ្នកតំណាងដោយអាណត្តិ៖** លោកមេធាវី [redacted] លោកស្រីមេធាវី [redacted] កញ្ញាមេធាវី [redacted] កញ្ញាមេធាវី [redacted] និងលោកមេធាវី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា [redacted]។

**+សហចុងចម្លើយ៖**

-ឈ្មោះ [redacted]ឌី ភេទប្រុស កើតឆ្នាំ១៩៥៧ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។

-ឈ្មោះ [redacted]ធារី ភេទស្រី កើតឆ្នាំ១៩៦៣ កាន់សៀវភៅគ្រួសារលេខ០៧១៣២៤ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ អ្នកទាំងពីរ មានអាសយដ្ឋានស្ថិត [redacted]។

**+អ្នកតំណាងដោយអាណត្តិ៖ គ្មាន**

**ក-ខ្លឹមសារសាលក្រម៖**

**ក.១-ខ្លឹមសារសាលក្រមដែលទាមទារដោយដើមចោទ៖**

ដើមចោទស្នើសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យសហចុងចម្លើយសងប្រាក់មកដើមចោទនូវប្រាក់ជំពាក់ដូចខាងក្រោម៖



Scanned with CamScanner

I. បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិហ៊ីប៉ូតែកលើអចលនវត្ថុដូចខាងក្រោម៖

១.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០៦-១០២៥ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិជើងឡង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

២.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៨១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៣.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៧៤ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយ -កម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៤.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៧៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

II.បង្គាប់ឱ្យចុងចម្លើយរួមគ្នាសងប្រាក់ដែលនៅជំពាក់ទាំងអស់មកឱ្យដើមចោទរួមមាន៖

១. ប្រាក់ដើមសរុបចំនួន USD ២០១.៧១១,៨១ (**ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន**)។

២. ការប្រាក់គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់ ០៩% (**ប្រាំបួនភាគរយ**) ក្នុងមួយឆ្នាំ លើប្រាក់ដើមសរុបចំនួន USD ២០១.៧១១,៨១ (**ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន**)។

៣. សំណងនៃការខូចខាត (ការប្រាក់ពិន័យ) គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រា១៨% (**ដប់ប្រាំបីភាគរយ**) ក្នុងមួយឆ្នាំ លើប្រាក់ដើមសរុបចំនួន USD ២០១.៧១១,៨១ (**ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន**)។

៤. សេវាកម្មច្បាប់ និងការខាតបង់ពេលវេលាចំនួន USD ១០.០០០ (**ដប់ពាន់ដុល្លារអាមេរិកគត់**)។

៥. ប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់ចុងចម្លើយ។

៦. សាលក្រមនេះអាចអនុវត្តបណ្តោះអាសន្នបានត្រង់ចំនុចទីII (១, ២ និង៣) ខាងលើ។

**ខ-អង្គហេតុ និងចំណុចវិវាទ៖**

**ខ.១-សេចក្តីសង្ខេប៖**

កាលថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] និងឈ្មោះ [redacted] បានចុះកិច្ចសន្យាខ្ចីបរិភោគ (រួម) ពី [redacted] ដែលមានទឹកប្រាក់សរុបចំនួន USD ២២០.០០០ (**ពីររយម្ភៃពាន់ដុល្លារអាមេរិកគត់**) តាមអត្រាការប្រាក់ ០៩% (**ប្រាំបួនភាគរយ**) ក្នុងមួយឆ្នាំ រយៈពេលខ្ចីប្រាក់៨៤ខែ ដោយធ្វើការបង់រំលស់ប្រាក់ដើម និងការប្រាក់ថេរចំនួន USD ៣.០០០ (**បីពាន់ដុល្លារអាមេរិកគត់**) ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ និងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៦ សងផ្តាច់ប្រាក់ដើមនិងការប្រាក់ដែលនៅសល់សមតុល្យជាក់ស្តែង។ របៀបនៃការសងប្រាក់ត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ **ធនាគារ** ដោយការសងប្រាក់ដើម និងការប្រាក់មួយលើកៗ ត្រូវកាត់យកជាស្វ័យប្រវត្តិពីគណនីរបស់ចុងចម្លើយដូចមានចែងក្នុងកិច្ចសន្យា ប្រការ១.២.១ នៃ ឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគ (រួម) លេខ ៤៨៧/២០១៩ ត.ទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩។



Scanned with CamScanner

**ខ.២-អង្គហេតុដែលគ្មានវិវាទៈ**

១-ដើមចោទ និងសហចុងចម្លើយ បានទទួលស្គាល់អត្ថិភាព នៃកិច្ចសន្យាខ្ចីបរិភោគ (រូម) លេខៈ ៤៨៧/២០១៩ ត.ម ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ពិតមែន គ្រាន់តែសហចុងចម្លើយមិនមានលទ្ធភាពសងនាពេលនេះ។

**ខ.៣-ចំណុចវិវាទៈ**

១/.តើដើមចោទអាចប្តឹងទាមទារប្រាក់កម្ចីពីសហចុងចម្លើយបានដែរ ឬទេ? ឬត្រូវទុកពេលវេលាឱ្យសហចុងចម្លើយរកប្រាក់សងដើមចោទវិញ?

២/.តើមានអត្ថិភាពនៃអង្គហេតុស្តីពីការប្រាក់ដែរ ឬទេ?

៣/.តើមានអត្ថិភាពនៃអង្គហេតុស្តីពីការប្រាក់ពិន័យដែរ ឬទេ?

៤/.តើដើមចោទទទួលរងនូវការខូចខាតផ្នែកជម្ងឺចិត្តការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ដែរឬទេ?

៥/.តើមានភាពចាំបាច់ដែលត្រូវប្រកាសឱ្យអនុវត្តសាលក្រមជាបណ្តោះអាសន្នដែរ ឬទេ?។

**ខ.៤-ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទៈ**

*ខ.៤.១-ការអះអាងរបស់ភាគីដើមចោទៈ*

លោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍ថាៈកាលថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] ឪ និងឈ្មោះ [redacted] ឆវី បានចុះកិច្ចសន្យាខ្ចីបរិភោគ(រូម)ពី [redacted] ដែលមានទឹកប្រាក់សរុបចំនួន USD ២២០.០០០ (**ពីររយម្ភៃពាន់ដុល្លារអាមេរិកគត់**) តាមអត្រាការប្រាក់០៩% (**ប្រាំបួនភាគរយ**) ក្នុងមួយឆ្នាំ រយៈពេលខ្ចីប្រាក់៨៤ខែ ដោយធ្វើការបង់រំលស់ប្រាក់ដើម និងការប្រាក់ថេរចំនួន USD ៣.០០០ (**បីពាន់ដុល្លារអាមេរិកគត់**) ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ និងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៦ សងផ្តាច់ប្រាក់ដើម និងការប្រាក់ដែលនៅសល់សមតុល្យជាក់ស្តែង។ របៀបនៃការសងប្រាក់ត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ ធនាគារ ដោយការសងប្រាក់ដើម និងការប្រាក់មួយលើកៗ ត្រូវកាត់យកជាស្វ័យប្រវត្តិពីគណនីរបស់ចុងចម្លើយ ដូចមានចែងក្នុងកិច្ចសន្យាប្រការ ១.២.១ នៃឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគ (រូម) លេខ ៤៨៧/២០១៩ ត.ម ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩។

ដើម្បីធានាបំណុលចុងចម្លើយបានដាក់ធានានូវអចលនវត្ថុរបស់ខ្លួនដូចខាងក្រោមៈ

១.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០៦-១០២៥ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិជើងឡង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

២.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៨១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៣.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៧៤ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៤.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៧៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។



Scanned with CamScanner

ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ចុងចម្លើយមិនបានគោរពកាតព្វកិច្ចនៃការបង់ប្រាក់តាមកិច្ចសន្យាឡើយ ដោយបានខកខានបង់ប្រាក់ដើម និងការប្រាក់ ជូនធនាគារអស់ជាច្រើនខែ ទោះបីជា **ធនាគារ** បានធ្វើការក្រើនរំលឹកជាច្រើនលើកច្រើនសារក៏ដោយ ក៏ចុងចម្លើយនៅតែមិនព្រមអនុវត្តកាតព្វកិច្ចនោះដែរ។

យោងតាមតារាងបញ្ជាក់ពីស្ថានភាពបំណុលរបស់ [redacted] បំណុលរបស់ឈ្មោះ [redacted] **ឌី** និងឈ្មោះ [redacted] **ឆវី** នៅជំពាក់ប្រាក់ដើមសរុបចំនួន USD ២០១.៧១១,៨១ **(ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន)** រួមទាំងការប្រាក់ និងការប្រាក់ពិន័យ (សំណងនៃការខូចខាត) គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០។ ការខកខានមិនបានសងបំណុលតាមការកំណត់ក្នុងតារាងកាលវិភាគសងប្រាក់នៃកិច្ចសន្យា គឺជាការបំពានកាតព្វកិច្ចដែលមានចែងក្នុងឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគ (រូម) លេខ៤៨៧/២០១៩ ឥ.ទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ត្រង់ប្រការ ៣(៣-២ និង ៣-៥)៖ *ភាគី -ក- (ចុងចម្លើយ) យល់ព្រមឱ្យភាគី-ខ- (ធនាគារ) ប្តឹងរំលាយកិច្ចសន្យាខ្ចីបរិភោគទាំងអស់ ហើយភាគី -ក- យល់ព្រមទូទាត់ប្រាក់ដែលជំពាក់មកភាគី-ខ- វិញទាំងអស់ រួមទាំងសំណងនៃការខូចខាត ការប្រាក់ និងប្រាក់ដើម ដោយគ្មានការតវ៉ាណាមួយឡើយ ក្នុងករណីភាគី-ក- បានបំពានកិច្ចសន្យា ឬខកខានបង់ប្រាក់ ឬប្រព្រឹត្តសកម្មភាពណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពសងបំណុល ឬប៉ះពាល់ដល់សិទ្ធិជាម្ចាស់បំណុលនោះ.........។ ករណីអចលនវត្ថុហ៊ីប៉ូតែកត្រូវបានរឹបអូសលក់ដោយបង្ខំតាមនីតិវិធីច្បាប់ ហើយបំណុលនៅតែសងមិនទាន់គ្រប់នោះភាគី -ក- សុខចិត្តបំពេញកាតព្វកិច្ចសងបន្ថែមរហូតទាល់តែគ្រប់ចំនួន។ ក្នុងករណីនេះភាគី -ក- ក៏យល់ព្រមឱ្យភាគី -ខ- មានសិទ្ធិប្តឹងរឹបអូសចលនវត្ថុ ឬអចលនវត្ថុផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ខ្លួនដើម្បីទូទាត់បំណុលឱ្យគ្រប់ចំនួនរួមទាំងប្រាក់សំណងនៃការខូចខាតការប្រាក់ និងប្រាក់ដើម-។*

ដូច្នេះ ធនាគារ មានសិទ្ធិគ្រប់គ្រាន់ក្នុងការប្តឹងសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងសហចម្លើយសងប្រាក់ដែលជំពាក់រួមមាន៖ ប្រាក់ដើម ការប្រាក់ សំណងការខូចខាត (ការប្រាក់ពិន័យ) និងថ្លៃចំណាយផ្សេងៗដូចជាសេវាកម្មច្បាប់ និងការខាតបង់ពេលវេលាជាដើម និងសុំអនុវត្តបណ្តោះអាសន្នលើបំណុលខាងលើនេះ។

*១.៤.២-<u>ការអះអាងរបស់ភាគីសហចុងចម្លើយ</u>*

-សហចុងចម្លើយឈ្មោះ [redacted] **ឆវី** បានធ្វើសេចក្តីថ្លែងការណ៍តបថា៖ ឈ្មោះ [redacted] **ឌី** បានទទួលដំណឹងពីដីកាកោះរបស់តុលាការផងដែរ ប៉ុន្តែគាត់រវល់។ នៅក្នុងរឿងនេះនាងខ្ញុំទទួលស្គាល់នូវប្រាក់ដើមដែលនៅជំពាក់ចំនួន USD ២០១.៧១១,៨១ **(ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន)** រួមទាំងការប្រាក់គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់ ០៩% (ប្រាំបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមសរុបចំនួន USD ២០១. ៧១១,៨១ **(ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន)** ហើយនាងខ្ញុំទទួលស្គាល់ការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រា ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើម សរុបចំនួន USD ២០១.៧១១,៨១ **(ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន)**។ នាងខ្ញុំ និងប្តីនាងខ្ញុំបានព្យាយាមអនុវត្តកាតព្វកិច្ច ហើយបានបង់ការប្រាក់បានប្រហែលជាច្រើនខែដែរទៅធនាគារកាណាឌីយ៉ា ក.អ តែដោយសារក្រោយមកស្រុកទេសកើតជម្ងឺកូវីដ-១៩ ទើបខ្លួនមិនមានលទ្ធភាពបង់ការប្រាក់ និងប្រាក់ដើមបន្តទៀត ហើយការរកស៊ីជំនួញខ្ញុំក៏ខាតបង់ទៀត ហេតុនេះសូមឱ្យខាងធនាគារការណាឌីយ៉ា ក.អ ពន្យាការទារបំណុលភ្លាមៗ។ នាងខ្ញុំសុំឱ្យខាងធនាគារលើកលែងការប្រាក់ និងប្រាក់ពិន័យដោយនាងខ្ញុំអស់លទ្ធភាពនឹងសង ហើយខ្ញុំនឹងព្យាយាមសងប្រាក់ដើមតាមលទ្ធភាពពេលនេះខ្លួនសុំដកឃ្លាលក់ដី ហើយពេលដែលខ្លួនលក់ដីដាច់ គឺខ្លួននឹងសងប្រាក់ដើមទៅខាងធនាគារវិញគ្រប់ចំនួន។ ពេលនេះខ្លួនបានចរចាជាមួយខាងធនាគារកាណាឌីយ៉ាសាខាក្រុងសួង គឺខ្លួនសូមស្នើសុំបង់ការប្រាក់ ១,០០០ ថ្ងៃ ដែលមានចំនួន ៤៦,៤៩៦ (បួនម៉ឺនប្រាំមួយពាន់បួនរយកៅសិបប្រាំមួយ) ដុល្លារអាមេរិក ហើយបន្ទាប់មកខាងធនាគារទុកពេលឱ្យនាង

ខ្ញុំចំនួន៩ខែ ដើម្បីខាងនាងខ្ញុំលក់ដីដាច់ពោលគឺនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ទើបខ្លួនអាចមានជម្រើស៣គឺ ទី១ អាចសងផ្តាច់ទៅខាងធនាគារ, ទី២រៀបឥណទានថ្មីឡើងវិញ និងទី៣បង់ការប្រាក់ និងប្រាក់ដើមទៅខាងធនាគារតាមឥណទានចាស់ដដែល។ ខ្ញុំទទួលស្គាល់ប្រាក់ដើមដែលនៅសល់ ការប្រាក់ និងប្រាក់ពិន័យ តែនៅក្នុងរឿងនេះខ្ញុំសុំទៅខាងធនាគារកាណាឌីយ៉ា ក.អ ដោយសុំបង់តែប្រាក់ដើមតែប៉ុណ្ណោះ ព្រោះខ្ញុំពុំមានលទ្ធភាពបង់ការប្រាក់ និងប្រាក់ពិន័យនោះទេ។ ចំពោះការទាមទារចំនួន ១០,០០០ (មួយម៉ឺនដុល្លារ) អាមេរិក ដោយសារការចំណាយសេវាមេធាវីសោហ៊ុយធ្វើដំណើរ និងកិច្ចការងារផ្សេងៗទៀត ដែលភាគីដើមចោទគាត់អះអាងនោះ នាងខ្ញុំទទួលស្គាល់តែសុំតុលាការពិចារណាបន្ធូរបន្ថយឱ្យនៅទាបបំផុត ព្រោះនាងខ្ញុំពុំមានលទ្ធភាពសងជម្ងឺចិត្តដើមចោទនោះទេ។ ចំពោះការទាមទារប្រាក់ប្រដាប់ក្តី និងការអនុវត្តជាបណ្តោះអាសន្នសូមឱ្យតុលាការពិចារណាតាមច្បាប់។

## ការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយ

-លោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយថា ខ្លួនសំណូមពរសុំឱ្យតុលាការចេញសាលក្រមសម្រេចតាមការទាមទាររបស់ធនាគារដែលមានខ្លឹមសារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ និងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ទុកជាបានការដដែល។

-សហចុងចម្លើយឈ្មោះ [redacted] ឌី និងឈ្មោះ [redacted] ឆវី បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយថា ការទាមទាររបស់ដើមចោទជាច្រើនចំណុចខាងលើមានលក្ខណៈធ្ងន់ធ្ងរដូច្នេះស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់។

**គ-អំពីវត្ថុតាង៖**

១.តារាងបញ្ជាក់ពីស្ថានភាពបំណុល ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ចំនួន ០១ ច្បាប់។

២.តារាងរំលស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ចំនួន ០១ ច្បាប់។

៣.កិច្ចសន្យាខ្ចីបរិភោគ(រួម)លេខ ៤៨៧/២០១៩ ឥ.ទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ចំនួន ០១ ច្បាប់។

៤.ឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគ(រួម)លេខ ៤៨៧/២០១៩ ឥ.ទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ចំនួន ០១ ច្បាប់។

៥.តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩ ចំនួន ០១ ច្បាប់។

៦.កិច្ចសន្យាបង្កើតហ៊ីប៉ូតែក(រួម) ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ចំនួន ០១ ច្បាប់។

៧.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៦០១០៦-១០២៥ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ចំនួន ០១ ច្បាប់។

៨.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៦០១០២-០៣៨១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ចំនួន ០១ ច្បាប់។

៩.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៦០១០២-០៣៧៤ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ចំនួន ០១ ច្បាប់។

១០.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៦០១០២-០៣៧៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ចំនួន ០១ ច្បាប់។

១១.លិខិតជូនដំណឹងសងប្រាក់(លើកទី១) ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។

១២.លិខិតជូនដំណឹងសងប្រាក់(លើកទី២) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។

១៣.លិខិតជូនដំណឹងសងប្រាក់(លើកទី៣) ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។

១៤.លិខិតជូនដំណឹងអំពីការបំពានកាតព្វកិច្ចសងបំណុល ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ ចំនួន ០១ ច្បាប់។



Scanned with CamScanner

១៥.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនិងសៀវភៅគ្រួសាររបស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ។

## សំអាងហេតុ

### ក-ការវិនិច្ឆ័យអំពីចំណុចវិវាទទី១ និងការទាមទារប្រាក់ដើម ៖

តើដើមចោទអាចប្តឹងទាមទារប្រាក់កម្ចីពីសហចុងចម្លើយបានដែរ ឬទេ? ឬត្រូវទុកពេលវេលាឱ្យសហចុងចម្លើយរកប្រាក់សងដើមចោទវិញ?

១-តាមការអះអាងរបស់ភាគីដើមចោទ និងសហចុងចម្លើយ និងការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួមមាន៖ តារាងបញ្ជាក់ពីស្ថានភាពបំណុល ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១, តារាងរំលស់ប្រាក់ដើម និងការប្រាក់ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១, កិច្ចសន្យាខ្ចីបរិភោគ (រូម) លេខ ៤៨៧/ ២០១៩ ឥ.ទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩, ឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគ (រូម) លេខ ៤៨៧/២០១៩ ឥ.ទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩, តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩, កិច្ចសន្យាបង្កើតហ៊ីប៉ូតែក (រូម) ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ បញ្ជាក់ឱ្យឃើញថា សហចុងចម្លើយពិតជាបានបង្កើតកិច្ចសន្យាខ្ចីចងការប្រាក់ ព្រមទាំងបានទទួលប្រាក់កម្ចីពីដើមចោទប្រាកដមែន។

២-ភាគីសហចុងចម្លើយបានថ្លែងការណ៍ថា ចំពោះការប្តឹងទាមទាររបស់ធនាគារដែលស្នើសុំឱ្យពួកខ្លួនរួមគ្នាសងប្រាក់ជំពាក់សរុបចំនួន USD ២០១.៧១១,៨១ (**ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន**) នោះពួកខ្លួនទទួលស្គាល់ការទាមទារនេះ។ ប៉ុន្តែសុំឱ្យធនាគារអនុគ្រោះចំពោះការទាមទារឱ្យពួកខ្លួនសងនៅពេលនេះ ព្រោះពួកខ្លួនមិនមានលទ្ធភាពសងតាមការទាមទាររបស់ដើមចោទទេ នោះគឺបញ្ជាក់បានថាសហចុងចម្លើយបានទទួលស្គាល់នូវអត្ថិភាព និងចំនួននៃទឹកប្រាក់ជំពាក់ដូចការអះអាងរបស់ដើមចោទពិតមែន។ ហេតុដូច្នេះគប្បីតុលាការទទួលស្គាល់នូវអង្គហេតុជំពាក់ និងអត្ថិភាព ព្រមទាំងចំនួននៃទឹកប្រាក់ ដោយពុំចាំបាច់ពិនិត្យលើភស្តុតាងស្របតាមកថាខណ្ឌទី២ មាត្រា១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣-ការដែលសហចុងចម្លើយមិនព្រមសងប្រាក់ខាងលើនៅពេលនេះ ដោយមូលហេតុថា ខ្លួនមិនមានលទ្ធភាពសងតាមការទាមទាររបស់ដើមចោទទេ ដោយសារតែមុខរបររកស៊ីចុងភៅការបុណ្យរបស់ពួកខ្លួនត្រូវខូចខាត ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ គឺជាការអះអាងមិនត្រឹមត្រូវទេ ព្រោះថាភាគីសហចុងចម្លើយបានបំពានលើករណីយកិច្ចរបស់ខ្លួនជាកូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច ដែលតាមបញ្ញត្តិមាត្រា៣៨៤ (ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច) នៃក្រមរដ្ឋប្បវេណីចែងថា **"កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់"** ហើយតាមរយៈនេះ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការបានតាមបញ្ញត្តិមាត្រា៣៨៥ (សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច) នៃក្រមរដ្ឋប្បវេណី។

ដូច្នេះ តុលាការទទួលស្គាល់នូវការប្តឹងទាមទារឱ្យសងប្រាក់របស់ដើមចោទនៅពេលនេះ និងសម្រេចឱ្យសហចុងចម្លើយសងប្រាក់ដើម តាមការទាមទាររបស់ដើមចោទទុកជាការទាមទារត្រឹមត្រូវ។

### ខ-ការវិនិច្ឆ័យអំពីចំណុចវិវាទទី២ ការទាមទារការប្រាក់៖

តើមានអត្ថិភាពនៃអង្គហេតុស្តីពីការប្រាក់ដែរ ឬទេ?

១-ទាក់ទិននឹងការទាមទាររបស់ដើមចោទលើការប្រាក់ដែលនៅជំពាក់ក្នុងអត្រា ០៩% (**ប្រាំបួនភាគរយ**) ក្នុងមួយឆ្នាំ លើប្រាក់ដើមសរុបចំនួន USD ២០១. ៧១១,៨១ (**ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន**) គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់នោះ តុលាការយល់ឃើញថាជាការទាមទារត្រឹមត្រូវ ព្រោះកិច្ចសន្យានេះត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងដើមចោទ និងសហចុងចម្លើយ និងធ្វើឡើងដោយភ្ជាប់ការប្រាក់ ដោយបានកំណត់អត្រាការប្រាក់ជាលាយល័ក្ខណ៍អក្សរច្បាស់លាស់ និងត្រឹមត្រូវតាម



Scanned with CamScanner

ច្បាប់ ស្របតាមបញ្ញត្តិមាត្រា៥៧៩ (ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ) និងមាត្រា៥៨៣ (សិទ្ធិលើបំណុលដែលជាការប្រាក់) នៃក្រមរដ្ឋប្បវេណី និងស្របតាមប្រការ ៤ នៃប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទានលេខ **ធ៧-០១៧-១០៩ ប្រ.ក** ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា (ដែលមានប្រសិទ្ធភាពអនុវត្តចំពោះកិច្ចសន្យាឥណទានថ្មី រួមទាំងឥណទានរៀបចំឡើងវិញ ដែលចុះកាលបរិច្ឆេទចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧) ដែលកំណត់ឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារមានសិទ្ធិក្នុងការកំណត់អត្រាការប្រាក់មិនឱ្យលើសពី១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ។

២-ចំពោះថិរវេលានៃការគិតការប្រាក់បន្តពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃសងគ្រប់ចំនួន តុលាការយល់ឃើញថា ដរាបណាសហចុងចម្លើយមិនទាន់សងប្រាក់រួចរាល់ ការគណនាការប្រាក់ត្រូវធ្វើជាបន្តតាមសមាមាត្រនៃអត្រាការប្រាក់គុណនិងប្រាក់ដើមដែលនៅជំពាក់រហូតដល់ថ្ងៃសងគ្រប់។

-តាមរយៈសំអាងហេតុខាងលើ បានបង្ហាញឱ្យឃើញថា ភាគីសហចុងចម្លើយពិតជាមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាកូនបំណុលក្នុងការទូទាត់សងប្រាក់ទៅឱ្យដើមចោទតាមកាលកំណត់ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃកិច្ចសន្យាខ្ចីបរិភោគលេខ៤៨៧/២០១៩ ឥ.ទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ប្រាកដមែន។ ហេតុដូច្នេះ តុលាការទទួលស្គាល់នូវការប្តឹងទាមទារការប្រាក់តាមការទាមទាររបស់ដើមចោទ ទុកជាការទាមទារត្រឹមត្រូវ។

**គ-ការវិនិច្ឆ័យអំពីចំណុចវិវាទទី៣ ការទាមទារប្រាក់ពិន័យ៖**

តើមានអត្ថិភាពនៃអង្គហេតុស្តីពីការប្រាក់ពិន័យ ដែរ ឬទេ?

១-ភាគីសហចុងចម្លើយបានបដិសេធ ចំពោះការទាមទារសំណងនៃការខូចខាត (ការប្រាក់ពិន័យ) ក្នុងអត្រា១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមសរុបចំនួន USD ២០១.៧១១,៨១ (**ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកក្បៀសប៉ែតសិបមួយសេន**) គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ដោយហេតុថា ពួកខ្លួនមិនមានលទ្ធភាពសងប្រាក់ទៅដើមចោទទេ ហើយការទាមទារត្រង់ចំណុចទាំងនេះមានចំនួនច្រើនលើសលប់ពេក ក្នុងករណីដែលតុលាការសម្រេចឱ្យពួកខ្លួនទទួលរ៉ាប់រងត្រង់ចំណុចនេះទៀត វារឹតតែជាបន្ទុកធ្ងន់ធ្ងរបន្ថែមទៀតសម្រាប់ពួកខ្លួននោះ តុលាការពិនិត្យឃើញថា ការលើកឡើងរបស់សហចុងចម្លើយនេះពុំមានមូលហេតុត្រឹមត្រូវឡើយ ដោយហេតុថាក្រៅពីការទាមទារការប្រាក់ ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន ស្របតាមបញ្ញត្តិមាត្រា ៣៩៨ ដល់មាត្រា ៤០៦ នៃក្រមរដ្ឋប្បវេណី។

២-ជាមួយគ្នានេះ គូភាគីក៏បានកំណត់ជាមុននូវចំនួននៃសំណងការខូចខាត ដូចមានចែងក្នុងប្រការ ៣ (៣.១) នៃឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគរួមលេខ ៤៨៧/២០១៩ ឥទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ បានចែងថា *"ករណីភាគីកូនបំណុលខកខាន ឬយឺតយ៉ាវក្នុងការទូទាត់សងឥណទានតាមកាលកំណត់ដូចក្នុងតារាងបង់ប្រាក់នោះ ភាគីកូនបំណុលយល់ព្រមបង់ប្រាក់សំណងនៃការខូចខាតតាមចំណុច ១.៤ ក្នុងប្រការ ១ នៃកិច្ចសន្យាខ្ចីបរិភោគយោងខាងលើដោយគិតចាប់ពីថ្ងៃដែលបានខកខានសងរហូតដល់បំណុលសងបញ្ចប់ទាំងស្រុង"* គឺជាខចែងពិសេសដែលគូភាគីបានព្រមព្រៀងអំពីការកំណត់ជាមុននូវចំនួននៃសំណង ក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ស្របតាមបញ្ញត្តិមាត្រា ៤០៣ នៃក្រមរដ្ឋប្បវេណី ដែលតុលាការមិនអាចបន្ថែម ឬបន្ថយចំនួននេះបានទេ (លើកលែងតែចំនួននេះច្រើនហួសហេតុពេកឬតិចហួសហេតុពេក)។ តាមរយៈនេះយោងតាមប្រកាសលេខ១២៨ **កយ.ប្រក/១១** ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត បានកំណត់អំពីអត្រាសំណងនេះមិនលើសពី **២៧%** (**ម្ភៃប្រាំពីរភាគរយ**) ក្នុងមួយឆ្នាំ ហើយការទាមទាររបស់ដើមចោទមានអត្រាការប្រាក់ស្មើនឹង ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ នោះគឺជាការទាមទារត្រឹមត្រូវស្របតាមកម្រិតរបស់ច្បាប់ ដូច្នេះតុលាការត្រូវសម្រេចអំពីការទាមទារប្រាក់ពិន័យក្នុងអត្រា១៨% (**ដប់ប្រាំបីភាគរយ**) ក្នុងមួយឆ្នាំ គិតលើប្រាក់ដើមខាងលើ។



Scanned with CamScanner

៣-យោងតាមតារាងបញ្ជាក់ពីស្ថានភាពបំណុល ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលចេញដោយធនាគារ កាណាឌីយ៉ា ក.អ បានបញ្ជាក់ថា សហកូនបំណុលឈ្មោះ រ៉ាន់ ឌី និងឈ្មោះ ឡេង ឆវី ពិតជាបានខកខានសងប្រាក់ទៅដើមចោទចាប់តាំងពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ មកប្រាកដមែន ហើយបើពិនិត្យតាមប្រការ ៣ (៣.១) នៃឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគរូមលេខ ៤៨៧/២០១៩ ឥទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ដែលបានចែងថា *"ករណីភាគីកូនបំណុលខកខាន ឬយឺតយ៉ាវក្នុងការទូទាត់សងឥណទានតាមកាលកំណត់ដូចក្នុងតារាងបង់ប្រាក់នោះភាគីកូនបំណុលយល់ព្រមបង់ប្រាក់សំណងនៃការខូចខាតតាមចំណុច ១.៤ ក្នុងប្រការ ១ នៃកិច្ចសន្យាខ្ចីបរិភោគយោងខាងលើ ដោយគិតចាប់ពីថ្ងៃដែលបានខកខានសងរហូតដល់បំណុលសងបញ្ចប់ទាំងស្រុង"។* ដូច្នេះនាំឱ្យការកំណត់ថិរវេលានៃការគិតប្រាក់ពិន័យ ចាប់គិតពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ តទៅ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**ឃ-ការវិនិច្ឆ័យអំពីចំណុចវិវាទទី៤ ការទាមទារសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជំងឺចិត្ត៖**

តើដើមចោទទទួលរងនូវការខូចខាតផ្នែកជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ ដែរ ឬទេ?

ឆ្លើយតបទៅនឹងការទាមទារ ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជំងឺចិត្ត មានចំនួនសរុប USD ១០.០០០ (**មួយម៉ឺនដុល្លារអាមេរិកគត់**) ដែលភាគីសហចុងចម្លើយបានបដិសេធចំពោះការទាមទាររបស់ភាគីដើមចោទទាំងស្រុងនោះ តុលាការយល់ឃើញថា ការដែលសហចុងចម្លើយមិនព្រមអនុវត្តកាតព្វកិច្ចសងប្រាក់កម្ចីទៅឱ្យដើមចោទបែបនេះ គឺពិតជាធ្វើឱ្យដើមចោទមានការខាតបង់ថ្លៃសេវាកម្មច្បាប់ និងការខាតបង់ពេលវេលា ដោយសារតែសហចុងចម្លើយជាអ្នកមានកំហុសដែលមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ទោះបីជាដើមចោទបានជូនដំណឹងទៅសហចុងចម្លើយដើម្បីឱ្យអនុវត្តកាតព្វកិច្ចជាច្រើនសារ ក៏ដោយក៏សហចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចដដែល ហើយការបំពានកាតព្វកិច្ចនេះ បានធ្វើប៉ះពាល់ដល់លំហូរសាច់ប្រាក់របស់ដើមចោទមានការកក់ស្ទះផងដែរ។ ដូច្នេះគប្បីតុលាការសម្រេចឱ្យសហចុងចម្លើយសងសំណងការខូចខាតទៅឱ្យដើមចោទ ដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ច ទំហំនៃការខូចខាត និងជីវភាពរបស់សហចុងចម្លើយស្របតាមមាត្រា ៤០០ និងមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី។

**ង-ការវិនិច្ឆ័យអំពីចំណុចវិវាទទី៥ ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន៖**

តើមានភាពចាំបាច់ដែលត្រូវប្រកាសឱ្យអនុវត្តសាលក្រមជាបណ្ដោះអាសន្នដែរ ឬទេ?។

ពាក់ព័ន្ធនឹងការស្នើសុំរបស់ភាគីដើមចោទ ដែលបានស្នើសុំឱ្យតុលាការប្រកាសថាសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាននោះ តុលាការយល់ឃើញថា សាលក្រមនេះជាសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ និងមានភាពចាំបាច់សម្រាប់ដើមចោទជាធនាគារដែលចាំបាច់ត្រូវតែធានាឱ្យមានលំហូរសាច់ប្រាក់ល្អប្រសើរ និងមិនអាចទុកឱ្យមានបំណុលខូច ឬបំណុលដែលមិនអាចទារបានក្នុងរយៈពេលយូរនោះទេ។ ម្យ៉ាងវិញទៀតការទាមទារនេះទៀតសោតក៏មានមូលហេតុ និងភស្តុតាងបញ្ជាក់ការទាមទារត្រឹមត្រូវ និងច្បាស់លាស់ ដូច្នេះអាចឱ្យតុលាការធ្វើការប្រកាសថាសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានលើប្រាក់ដើម និងការប្រាក់ ដោយពុំចាំបាច់ឱ្យដាក់ប្រាតិភោគស្របតាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ច-ការវិនិច្ឆ័យអំពីការទាមទារ៖**

ដើមចោទបានប្ដឹងទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់អំពីអត្ថិភាព នៃសិទ្ធិហ៊ីប៉ូតែកលើអចលនវត្ថុដូចខាងក្រោម៖

១.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០៦-១០២៥ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិជើងឡង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។



Scanned with CamScanner

២.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៨១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៣.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៧៤ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៤.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៧៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

តាមរយៈនេះតុលាការយល់ឃើញថា តាមការពិនិត្យលើកិច្ចសន្យាខ្ចីបរិភោគ (រូម) លេខ ៤៨៧/២០១៩ ឥទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩, ឧបសម្ព័ន្ធ១ នៃកិច្ចសន្យាខ្ចីបរិភោគ (រូម) លេខ ៤៨៧/២០១៩ ឥទ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក (រូម) ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ បានបញ្ជាក់ថា សហចុងចម្លើយពិតជាបានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុខាងលើជាមួយដើមចោទប្រាកដមែន ស្របតាមមាត្រា៨៤៣ និង មាត្រា៨៤៤ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះគប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ ស្របតាមមាត្រា៨៤៦ នៃក្រមរដ្ឋប្បវេណី។

**ឆ-ការវិនិច្ឆ័យអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី៖**

ដោយហេតុថាការប្ដឹងទាមទារនេះកើតចេញពីកំហុសរបស់សហចុងចម្លើយដែលបានបំពានក្នុងការអនុវត្តកាតព្វ-កិច្ចនោះ គប្បីសម្រេចអំពីប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយស្របតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្របតាមការទាមទាររបស់ដើមចោទ។

**<u>សេចក្ដីសម្រេចបញ្ចប់៖</u>**

I.ដើមចោទ [redacted]មានអត្ថិភាពនៃសិទ្ធិហ៊ីប៉ូតែកលើអចលនវត្ថុដូចខាងក្រោម៖

១-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០៦-១០២៥ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិជើងឡង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

២-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៨១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៣-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៧៤ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៤-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២៥០៦០១០២-០៣៧៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ មានទីតាំងស្ថិតនៅភូមិធ្លក សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

II.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ឌី និងឈ្មោះ [redacted] ឆវី រួមគ្នាសងដោយកាតព្វកិច្ចសាមគ្គីទៅឱ្យដើម-ចោទ [redacted](ដោយមានលោក [redacted]រដ្ឋា ជាអ្នកតំណាង និងលោកមេធាវី [redacted] លោកស្រីមេធាវី



Scanned with CamScanner

[redacted]ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ) នូវប្រាក់ជំពាក់ដូចខាងក្រោម៖

១-ប្រាក់ដើមសរុបចំនួន USD ២០១.៧១១,៨១ (ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកគៀសប៉ែតសិបមួយសេន)។

២-ការប្រាក់៩% (ប្រាំបួនភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមសរុបចំនួន USD ២០១.៧១១,៨១ (ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកគៀសប៉ែតសិបមួយសេន) គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់។

៣-សំណងនៃការខូចខាត (ការប្រាក់ពិន័យ) ក្នុងអត្រា១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមសរុបចំនួន USD ២០១.៧១១,៨១ (ពីររយមួយពាន់ប្រាំពីររយដប់មួយដុល្លារអាមេរិកគៀសប៉ែតសិបមួយសេន) គិតចាប់ពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់។

៤-ថ្លៃសេវាកម្មច្បាប់ និងការខាតបង់ពេលវេលាចំនួន KHR ២០.០០០.០០០ (ម្ភៃលានរៀលគត់)។ ការទាមទារលើសពីនេះសម្រេចច្រានចោល។

៥-សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានគ្រប់ចំណុច៕ (ទី១ ប្រាក់ដើម និងទី២ ការប្រាក់) នៃសេចក្ដីសម្រេចបញ្ជាប់។

៦-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះត្រូវបានប្រកាសជាសាធារណៈនៅសវនាការទី៣ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេល០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃពុធ ១០រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ត្បូងឃ្មុំ, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា៖ [redacted]

---

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

*បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម*

ថ្ងៃពុធ ១០រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ត្បូងឃ្មុំ, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner